

ចេញពីការបដិសេធ មកឯការទទួលយក



Identification
ដោយ ដេរេក ព្រីនស៍

ខ្ញុំមានសេចក្តីរីករាយណាស់ដែលបានជួបអ្នកម្តងទៀត ដើម្បីចែករំលែកសេចក្តីពិតដ៏មានតម្លៃ និងការយល់ដឹងដ៏ជ្រាលជ្រៅ ដែលបានធ្វើឱ្យមានភាពខុសគ្នារវាងភាពជោគជ័យ និងបរាជ័យនៅក្នុងជីវិតរបស់ខ្ញុំ ហើយសេចក្តីពិតទាំងនេះក៏អាចធ្វើឱ្យមានការផ្លាស់ប្តូរដូចគ្នានៅក្នុងជីវិតរបស់អ្នកផងដែរ។

គោលស័ខាន់របស់យើងនៅក្នុងសប្តាហ៍នៃបុណ្យព្រះយេស៊ូវមានព្រះជន្មរលំឡើងវិញនេះ គឺ: ការទទួល យកអត្តសញ្ញាណ។ យើងកំពុងនិយាយអំពីការដោះដូរដែលសម្រេចបាន តាមរយៈការសុគតរបស់ព្រះយេស៊ូវ ជាអ្វីម្យ៉ាងដែលមិនអាចមើលឃើញដោយភ្នែកខាងសាច់ឈាម តែអាចយល់បានដោយសារជំនឿតែប៉ុណ្ណោះ ចេញពីសេចក្តីដែលបានចែងនៅក្នុងបទគម្ពីរ។ ប៉ុន្តែ នៅពេលព្រះយេស៊ូវសុគតលើឈើឆ្កាង មានអន្តរការណ៍ មួយដែលភ្នែកមិនអាចមើលឃើញ កើតឡើងនៅក្នុងពិភពខាងវិញ្ញាណ។ គ្រប់ទាំងសេចក្តីអាក្រក់ដែលត្រូវ ធ្លាក់មកលើយើង និងការមិនស្តាប់បង្គាប់របស់យើង បានធ្លាក់ទៅលើព្រះយេស៊ូវ ក្នុងនាមជាតំណាងរបស់យើង ជាលោកអ័ដាំ ចុងក្រោយ នៅពេលដែលព្រះអង្គត្រូវបានគេព្យួរនៅលើឈើឆ្កាង ទ្រង់ត្រឡប់ជាតួបណ្តាសាជំនួស យើង ដើម្បីឲ្យយើងបានទទួលគ្រប់ទាំងសេចក្តីល្អ ដែលនៅអស់កល្បជានិច្ចដោយសារព្រះយេស៊ូវ ដែលទ្រង់ជាកូនចៀមឥតស្លាកស្នាម គ្មានបាបសោះ ជាព្រះ រាជបុត្រារបស់ព្រះដែលស្តាប់បង្គាប់។ នោះហើយជាការដោះដូរ។ សេចក្តី អាក្រក់បានធ្លាក់លើព្រះយេស៊ូវ ដើម្បីឲ្យយើងបានទទួលសេចក្តីល្អ ដោយសារព្រះអង្គ។

ក្នុងការចែកចាយរបស់ខ្ញុំនៅសប្តាហ៍នេះ យើងបានមើលជាមួយគ្នាទៅឯចំណុចជាក់លាក់បី អំពីការដោះ ដូរ។ ទីមួយ គឺពីបណ្តាសា ទៅឯព្រះពរ។ ព្រះយេស៊ូវទទួលរងបណ្តាសា នៅពេលដែលព្រះអង្គត្រូវបានព្យួរនៅ លើឈើឆ្កាង ដើម្បីឲ្យយើងបានទទួលព្រះពរ។ ទីពីរ មកឯការប្រោសឲ្យជា។ ព្រះយេស៊ូវ បាន ទទួលយកភាពពិការ ការឈឺចាប់របស់យើង ហើយដោយស្នាមរបួសរបស់ទ្រង់ យើងបានទទួលការ ប្រោសឲ្យជា។ ទីបី គឺពីភាពក្រីក្រ មកឯសេចក្តីចម្រុងចម្រើន។ នៅពេលព្រះយេស៊ូវត្រូវបានគេព្យួរនៅលើ ឈើឆ្កាង ព្រះអង្គបានទទួលរងបណ្តាសានៃភាពក្រីក្រ។ យើងបានពិនិត្យមើលរឿងនេះជាមួយគ្នា នៅក្នុងវគ្គមុន រួចហើយ។ បណ្តាសានៃភាពត្រីក្រ ស្រេក អាក្រាត និងខ្វះខាតអ្វីទាំងអស់ ហើយប្រាកដជាស្លាប់ណាស់ នៅលើឈើឆ្កាង ព្រះយេស៊ូវបានសម្រេចគ្រប់ការទាំងអស់។ ទ្រង់ឃ្លាន ទ្រង់ស្រេក ទ្រង់អាក្រាត ទ្រង់ គ្មានអ្វីទាំងអស់ ដែលនោះមិនមែនជាការចៃដន្យឡើយ តែផ្អែកលើផែនការរបស់ព្រះវិញ។ បណ្តាសានៃភាព ក្រីក្រ បានធ្លាក់ទៅលើព្រះយេស៊ូវ ដើម្បីនាំការត្រឡប់មកវិញ គឺតាមរយៈជំនឿ យើងបានទទួលព្រះពរនៃភាពចម្រុងចម្រើន

ថ្ងៃនេះ យើងនឹងមើលទៅចំណុចមួយទៀតនៃការដោះ ដូរនេះ ដែលបានសង្ខេបជាឃ្លាមួយ ចេញពីការបោះបង់ មកការទទួលយក។

ខ្ញុំត្រូវចាប់ផ្តើមដោយពន្យល់អំពីន័យរបស់ពាក្យ ការបោះបង់។ នេះជាការដែលយើងទាំងអស់គ្នាធ្លាប់ជួបប្រទះ នៅក្នុងជីវិត ប៉ុន្តែជាញឹកញាប់ យើងមិនបានកត់សម្គាល់។ សម្រាប់ខ្លួនខ្ញុំផ្ទាល់ ខ្ញុំអាចនិយាយបានថា ការបោះបង់នេះ គឺជាបញ្ហាខាងអារម្មណ៍ និងខាងវិញ្ញាណដែលមនុស្សគ្រប់គ្នាជួបប្រទះច្រើនជាងតេបំជុត ហើយនាំឲ្យមានការឈឺចាប់នៅក្នុងវប្បធម៌សម័យកាលរបស់យើង។ តើពាក្យដែលខ្ញុំចង់និយាយនេះ មានន័យ ដូចម្តេច? ពាក្យនេះ អាចឲ្យនិយមន័យតាមរបៀបផ្សេងៗគ្នា ដោយប្រើឃ្លាផ្សេងៗគ្នា។ ជាសំខាន់ ការបោះបង់ គឺជាអារម្មណ៍ដែលគេមិនចង់បាន មានអារម្មណ៍មិនសក្តិសម ហាក់ដូចជាចូលនឹងគេ

មិនចុះ គឺបែបដូចជាមនុស្សដែលគេមិនរាប់រក ឬដូចជាមនុស្សក្រៅបញ្ជី។ ខ្ញុំគិតអំពីមនុស្សដែលឈឺចាប់ដោយរបួសនៃការបោះបង់នេះ ដូចជាមនុស្សម្នាក់ដែលតែងតែឈរនៅខាងក្រៅមើលមកក្នុង ជាម្នាក់ដែលចង់ស្ថិតនៅខាងក្នុង ជាម្នាក់ដែលចង់ធ្វើជាសមាជិករបស់គ្រួសារមួយ ជាផ្នែកនៃអំណរ ជាផ្នែកនៃការដែលគេទទួលយកបាន ជាផ្នែកនៃសេចក្តីស្រឡាញ់ ប៉ុន្តែ ជានិច្ចកាល មិនដឹងជាយ៉ាងម៉េច ចេះតែមានអារម្មណ៍ថាទៅមិនរួច ឬមិនសក្តិសមនឹងចូលបានដូចគេ។ ហើយជាមួយនឹងការបោះបង់នេះ ក៏នាំឲ្យមានការដទៃទៀតជាច្រើនចូលមក អារម្មណ៍ឯកោ វេទនា អានិតខ្លួនឯង ហើយជាញឹកញាប់ រឿងអាក្រក់ៗ ចូលមកថែមទៀត ដូចជាការអស់សង្ឃឹម និងការធ្វើអត្តឃាត ប៉ុន្តែការទាំងអស់នោះ កើតចេញពីឫសគល់ដីល្វីងជូរចត់នៃអារម្មណ៍នៃការបោះបង់។

ឥឡូវនេះ ស្ថានភាពនៃការបោះបង់នេះ ត្រូវបានពណ៌នាដោយឡែកៗពីគ្នានៅក្នុងព្រះគម្ពីរ ប៉ុន្តែ មាន ប្រភេទនៃការបោះបង់ជាទូទៅមួយ ដែលជារបស់អស់អ្នកដែលមិនមានការទាក់ទងត្រឹមត្រូវចំពោះព្រះ។ រឿង នេះ លោកប៉ុលបានពណ៌នានៅក្នុងគម្ពីរអេភេសូរ ជំពូក២ ខ១២។ លោកបានថ្លែងទៅកាន់ពួកអ្នកជឿ ដែល មិនមែនជាជនជាតិយូដា ដែលលោកបាននិយាយថា:

> នៅពេលនោះ អ្នករាល់គ្នាមិនមានព្រះគ្រីស្ទទេ ក៏ឃ្លាតចេញពីជនជាតិអ៊ីស្រាអែលផង ជាមនុស្សដទៃទាំង ឯសេចក្តីសញ្ញាដែលព្រះអង្គបានសន្យាទុក គ្មានទីសង្ឃឹម ហើយក៏គ្មានព្រះនៅក្នុងពិភពលោកនេះដែរ។

នេះជាពាក្យមិនល្អសោះនៅបុងខ គឺគ្មានទីសង្ឃឹម ហើយងាន់ព្រះ។ មែនហើយ គ្រប់គ្លាដែលងាន់ព្រះ គគ្មានទសង្ឃមទេ ហើយដែលគ្មានព្រះ នោះដូចជាមនុស្សបម្លែក ជាជនបរទេស ជាមនុស្សកព្រា ជា អ្នកដែលាន់ការផ្តត់ផ្តង់ច ពេញលេញ ជាអ្នកដែលមិនសក្តិសមនឹងស្ថិតនៅខាងក្នុង ជាអ្នកដែលនៅក្រៅរបង ដែលមើលមកខាងក្នុង ទាំងចិត្តប្រាថ្នាចង់បាន និងការរំពឹងទុកដែលមិនបានសម្រេច នោះហើយជាស្ថានភាព នៃអស់អ្នក ដែលតាមរយៈអំពើបាប បានបាត់បង់ទំនាក់ទំនងត្រឹមត្រូវមួយជាមួយព្រះ ជាអ្នកដែលត្រូវការការ ព្យះផ្សាឲ្យជានាជាមួយព្រះឡេងវញ។

យើងត្រូវចាំជាប់ក្នុងគំនិតថា នេះជាអំពើបាបរបស់យើងកាលពីដើម ដែលធ្វើឲ្យយើងមានហេតុនៃការ បោះបង់។ នៅក្នុងគម្ពីរហាបាគុក ជំពូក១ ខ១៣ ហោរាហាបាគុក ទូលទៅព្រះអម្ចាស់ជា៖

> ព្រះអង្គមានព្រះនេត្របរិសុទ្ធក្រៃលែង នឹងទតមើលការអាក្រក់មិនបាន។ (RKOV)

ដូច្នេះ ទីណាដែលការអាក្រក់ និងបាបចូលមក នោះព្រះទ្រង់នឹងងាកព្រះនេត្រចេញ។ ព្រះអង្គមិនអាចទទួលយកបានឡើយ។ ព្រះអង្គមិនអាចទទួលការនោះចូលមកក្នុងព្រះវត្តមានរបស់ព្រះអង្គបានឡើយ។ ព្រះអង្គច្រានការអាក្រក់ចោល។ សេចក្តីបរិសុទ្ធ និងសេចក្តីសុចរិតដែលគ្មានដែនកំណត់របស់ព្រះអង្គ គីចាំបាច់ត្រូវតែឲ្យព្រះអង្គច្រានចោលគ្រប់ទាំងសណ្ឋាននៃអំពើបាប សេចក្តីអាក្រក់ ទោសកំហុស ហើយដោយហេតុផលនោះ យើងកីស្ថិតនៅក្នុងស្ថានភាពនៃការបោះបង់នេះ ពីខាងក្រៅ ដូចមនុស្សចម្លែក មនុស្សក្រៅបញ្ជី។ ប៉ុន្តែ អរព្រះគុណព្រះ ការសុគតរបស់ព្រះយេស៊ូវ បានបំផ្លាស់បំប្រែការទាំងអស់នេះ ហើយនៅខបន្ទាប់ ក្នុងគម្ពីរ អេភេសូរ ជំពូក២ ខ១៣ លោកប៉ូលថ្លែងអំពីការបំផ្លាស់បំប្រែនេះថា៖

> តែឥឡូវនេះ នៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះអ្នករាល់គ្នា ដែលពីដើមនៅឆ្ងាយ បានមកជិតវិញ ដោយសារ ព្រះលោហិតរបស់ព្រះគ្រីស្ទ។ (RKOV)

នោះហើយជាការផ្លាស់ប្តូរពីការបោះបង់ មកឯការទទួលយក។ ពីមុនយើងនៅឆ្ងាយពីមុនយើងនៅ ខាងក្រៅរង្វង់គ្រួសារ ពីមុនយើងជាមនុស្សរក្រៅបញ្ជី ពីមុនយើងជាជនចម្លែក និងជាជនបរទេស ពីមុនយើង គ្មានសិទ្ធិ។ ប្រសិនបើយើងបានចូលមកឯព្រះ ក្នុងស្ថានភាពគ្រប់យ៉ាងបែបនោះ ក្នុងភាពជាអ្នកសុំទាន មិនមែន តែឥឡូវនេះ តាមរយៈការសុគតរបស់ព្រះយេស៊ូវ តាមរយៈការខ្ចាយព្រះលោហិតរបស់ព្រះអង្គ យើង ដែលពីមុននៅឆ្ងាយ ត្រូវបាននាំចូលមកជិតព្រះវិញ។ នោះហើយជាការផ្លាស់ប្តូរ ពីការបោះបង់ មកឯការ ទទួលយក។ ព្រះយេស៊ូវបានបើកផ្លូវឲ្យមានការផ្លាស់ប្តូរនេះ ចេញពីការបោះបង់ មកឯការទទួលយក ដែលខ្ញុំកំពុងនិយាយ ព្រោះនៅលើឈើឆ្កាង ព្រះអង្គបានទទួលភាពដែលត្រូវបានបោះបង់របស់យើង។ តាម ពិត នោះជាភាពឈឺចាប់ចុងក្រោយរបស់ព្រះអង្គ។ នោះជាអ្វីដែលធ្វើឲ្យព្រះអង្គខ្ចេចខ្ចាំចិត្ត ហើយធ្វើឲ្យព្រះ អង្គសុគត។ ការនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងគម្ពីរដំណឹងល្អ នៅក្នុងកំណត់ត្រានៃការសុគតនៅលើ ឈើឆ្កាង។ សូមយើងមើលនៅក្នុងម៉ាថាយ ២៧ ខ៤៥ និងខ៤៦ អំពីកំណត់ត្រានៃការសុគតរបស់ព្រះអង្គនៅ លើឈើឆ្កាង:

> តាំងពីថ្ងៃត្រង់ រហូតដល់ម៉ោងបីរសៀល មេឃងងឹតគ្របដណ្តប់លើទឹកដីនោះទាំងមូល ហើយប្រហែលជាម៉ោងបី(រសៀលនោះ ព្រះយេស៊ូវស្រែកឡើងយ៉ាងខ្លាំងថា៖ «អេលី អេលី ឡាម៉ា សាបាច់ជានី!»

នោះជាភាសាអារ៉ាម។ នេះជាសេចក្តីដកស្រង់ចេញពីទំនុកតម្កើង ២២។ ពាក្យនេះមានន័យថា «ព្រះ នៃទូលបង្គំ ព្រះនៃទូលបង្គំអើយ! ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំ?» ពាក្យដែលព្រះយេស៊ូវបានស្រែកឡើង ជាភាសាអារ៉ាមនេះតែងតែប៉ះពាល់ចិត្តខ្ញុំជានិច្ច។ នេះជាហេតុការណ៍ដែលយើងត្រូវយល់ ហើយត្រូវពិសោធឲ្យដឹងថា នៅពេលមនុស្សកំពុងឈឺចាប់ដោយអត់សង្ឃឹម ហើយជាពិសេស ដល់ចំណុចដែលត្រូវស្លាប់ គំនិតរបស់គេ ជាញឹកញាប់ ត្រឡប់ទៅរកភាសាដើមដែលគេបានចេះកាលពីកុមារភាពរបស់ខ្លួន ហើយនោះជា របៀបដែលខ្ញុំយល់ពីហេតុការណ៍នោះ។ ព្រះយេស៊ូវបានប្រើភាសាកំណើតរបស់ព្រះអង្គ ជាភាសាដែលព្រះអង្គ បានរៀននៅក្នុងគ្រួសាររបស់ព្រះអង្គ។ ព្រះអង្គស្រែកឡើង តែមិនមែនស្រែករកមនុស្សទេ គឺចំពោះព្រះវិញ ព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ! ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំ?» សូមចាំថា ពេលនោះ គ្មានចម្លើយពីស្ថានសួគ៌ទេ។ នោះជាលើកដំបូងដែលព្រះយេស៊ូវទ្រង់អធិស្ឋាន ឬស្រែករកព្រះ ហើយមិនបានទទួលចម្លើយ។ ពេលនោះ ស្ថានសួគ៌ឆ្ងាត់ឈឹង។ ព្រះជាម្ចាស់បានងាកព្រះនេត្ររបស់ព្រះអង្គចេញ។ ព្រះ បានបិទព្រះការណ៍របស់ព្រះអង្គមិនព្រមស្តាប់។ ហេតុអ្វី? ព្រោះព្រះទ្រង់បរិសុទ្ធក្រៃលែង នឹងទតមកលើអំពើ បាបមិនបានទេ ក៏មិនអាចលើកលែងទោសបានដែរ ហើយនៅពេលព្រះយេស៊ូវបានដាក់អង្គទ្រង់ជាមនុស្សមាន បាបដូចយើង ដោយព្រោះតែសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិតរបស់ព្រះអង្គ ព្រះទ្រង់ងាកព្រះនេត្ររបស់ព្រះ អង្គចេញ ហើយបិទព្រះការណ៍របស់ព្រះអង្គមិនព្រមស្តាប់ ក៏គ្មានចម្លើយពីស្ថានសួគ៌ដែរ។ លទ្ធផលនោះគឺ សម្រាប់ជាសេចក្តីល្អដល់យើង។ ហេតុការណ៍នេះ ត្រូវបានរៀបរាប់បញ្ជាក់យ៉ាងច្បាស់ នៅក្នុងគម្ពីរម៉ាថាយ ជំពូក២៧។ ខ៥១ ចែងថា៖

> គ្រានោះ វាំងននក្នុងព្រះវិហារក៏រហែកជា២ភាគ ចាប់តាំងពីលើចុះទៅដល់ក្រោម ក៏មានកក្រើកដី ហើយថ្មប្រេះដាច់ពីគ្នា។

តើវាំងននៅក្នុងព្រះវិហារនោះ តំណាងឲ្យអ្វី? គឺតំណាងឲ្យការខណ្ឌញែកពីគ្នារវាងព្រះដ៏បរិសុទ្ធ និងមនុស្សមានបាប ប៉ុន្តែតាមរយៈការសុគតរបស់ព្រះយេស៊ូវ ដោយព្រោះព្រះអង្គបានផ្ទុកភាពបោះបង់ជំនួស យើង ព្រះអង្គក៏សម្រេចបានឲ្យ

យើង នូវការទទួលយក ហើយភស្តុតាងនៃការទទួលយក គឺការរហែកវាំងនន នោះឯង ហើយវាំងនននោះរហែក ដូចជាបទគម្ពីរបានចែង គឺតាំងពីលើ ចុះដល់ក្រោម។ ហេតុការណ៍នេះ មិនមែនកើតឡើងដោយដៃមនុស្សទេ តែដោយសារព្រះទ្រង់ធ្វើវិញ។ ព្រះយេស៊ូវ បានទទួលរងនូវការបោះបង់ ចោលជំនួសយើង ដើម្បីឲ្យយើងបានចូលទៅក្នុងការទទួលយករបស់ព្រះអង្គ។ ឥឡូវនេះ ការទទួលយកតាមរយៈ ការសុគតរបស់ព្រះយេស៊ូវនេះ ត្រូវបានលោកប៉ុលពិពណ៌នាដោយឡែកៗពីគ្នា ជាពិសេសនៅក្នុងគម្ពីរអេភេសូរ ជំពូក១ ខ៤ ដល់ខ៨ ជាកន្លែងដែលលោកថ្លែងថា៖

> 4 តាមដែលទ្រង់បានរើសយើងរាល់គ្នាក្នុងព្រះគ្រីស្ទ តាំងពីមុនកំណើតលោកីយ៍មកប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់ ដោយសេចក្តីស្រឡាញ់ 5 ពីព្រោះទ្រង់បានតម្រូវយើងរាល់គ្នាទុកជាមុន សម្រាប់ឲ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះយេស៊ូវគ្រីស្ទ តាមបំណងព្រះហឫទ័យទ្រង់ 6 ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់ ដែលបានផ្តល់មកយើងរាល់គ្នាទទេ ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់ 7 ហើយយើងបានសេចក្តីប្រោសលោះនៅក្នុងព្រះរាជបុត្រានោះ ដោយសារព្រះលោហិតទ្រង់ គឺជាសេចក្តីប្រោសឲ្យរួចពីទោស តាមព្រះគុណដ៏ធ្ងន់ក្រៃលែងនៃទ្រង់ 8 ដែលបានផ្តល់មកយើងជាបរិបូរ ដោយនូវប្រាជ្ញា និងតម្រិះសព្វគ្រប់។

ខ្ញុំតែងតែចូលចិត្ត សំណៅ King James ដែលនៅក្នុងខនោះ បានចែងថា ព្រះទ្រង់បានធ្វើឲ្យយើងអាច ទទួលយកបាននៅក្នុងព្រះរាជបុត្រាស្ងួនភ្ងា»។ នោះជាសំណៅបកប្រែត្រង់ គឺចេញពីភាពដែលត្រូវបោះបង់ មកឯការទទួលយកជាកូនរបស់ព្រះ ជាសមាជិកនៃគ្រួសាររបស់ព្រះអង្គ។ ខ៧ លោកប៉ុលបន្តថា:

> នៅក្នុងព្រះអង្គគឺនៅក្នុងព្រះយេស៊ូវ យើងមានការប្រោសលោះតាមរយៈព្រះលោហិតរបស់ព្រះអង្គ គឺការ អត់ទោសពីអំពើរំលង ស្របតាមព្រះគុណដ៏ធ្ងន់ក្រៃលែងរបស់ព្រះអង្គ ដែលព្រះអង្គបានផ្តល់មកយើងជា បរិបូណ៌

សូមកត់សម្គាល់ពីការសង្កត់ធ្ងន់លើព្រះគុណ។ ព្រះគុណមិនមែនជារបស់ដែលអាចរកបានឡើយ។ សូមកត់សម្គាល់ពីការសង្កត់ធ្ងន់លើការប្រោលលោះ។ យើងមានការប្រោសលោះ តាមរយៈព្រះ លោហិតរបស់ព្រះអង្គ ប្រោសលោះពីបណ្តាសា មករីករាយនឹងព្រះពរ ប្រោសលោះពីភាពដែលត្រូវបាន បោះបង់ មករីករាយនឹងការទទួលយក។

យើងអស់ពេលសម្រាប់ថ្ងៃនេះហើយ។ ខ្ញុំនឹងត្រឡប់មកជួបលោកអ្នកជាថ្មីម្តងទៀតនៅវគ្គក្រោយ តាមពេលវេលា និងម៉ោងដដែល ហើយយើងនឹងមើលទៅឯការដោះដូរចុងក្រោយ ដែលបាន កើតឡើងនៅលើឈើឆ្កាង។

ផតខាស

ប្រតិចារិក: RP-R072-104-KHM
បច្ចុប្បន្នភាពចុងក្រោយ: 21 Nov 2026
គេហទំព័រ: Derekprince.com/km/resources

